ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភា
## ប្រចាំខែតុលា ឆ្នាំ២០១៨

*នៅក្នុងខែតុលា ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ*

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា ឬានៈ**

*-បំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទី ចាប់ពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៨*

*-អញ្ជើញចូលរួមប្រារព្ធព្រះរាជពិធីបុណ្យខួបគម្រប់៩ឆ្នាំ នៃការយាងចូលព្រះទិវង្គត* ***ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ " ព្រះបរមរតនកោដ្ឋ "*** *ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត នៅព្រះធម្មសាលា ក្នុងបរិវេណព្រះឧបោសថរតនារាម ព្រះកែវមរកត ព្រះបរមរាជវាំង*

*-អញ្ជើញទទួលព្រះរាជដំណើរ* ***ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី*** *ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍ពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់មាតុប្រទេសវិញ*

*-អនុញ្ញាតឱ្យឯកឧត្តម* ***អ៊ីង ស៊ាន*** *ឯកអគ្គរាជទូតតែងតាំងថ្មី នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅសាធារណរដ្ឋឥណ្ឌា ចូលជួបសម្តែងការគួរសម និងគោរពលាមុននឹងទៅបំពេញភារកិច្ច*

*-អញ្ជើញបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន*

*-អញ្ជើញគោរពវិញ្ញាណក្ខន្ធសពឯកឧត្តម* ***ត្រាន ដៃក្វាង*** *ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*

*-អញ្ជើញគោរពវិញ្ញាណក្ខន្ធ ចូលរួមរំលែកទុក្ខ និងចូលរួមបុណ្យគម្រប់ខួប៧ថ្ងៃ ឧទ្ទិសកុសលជូនចំពោះដួងវិញ្ញាណក្ខន្ធសព ឯកឧត្តម* ***នៃ ប៉េណា*** *អតីតអនុប្រធានទី១ ព្រឹទ្ធសភា*

*-អញ្ជើញជាកិត្តិយសប្រទានភ្លើងបូជាសពឯកឧត្តម* ***នៃ ប៉េណា*** *អតីតអនុប្រធានទី១ ព្រឹទ្ធសភា នៅទីមេរុ មុខវត្តបទុមវត្តី សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ*

-អញ្ជើញបំពាក់គ្រឿងឥស្សរិយយសជាកិច្ចបច្ឆាមរណៈជូនឯកឧត្តម **នៃ ប៉េណា** អតីតអនុប្រធានទី១ ព្រឹទ្ធសភា

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដួងវិញ្ញាណក្ខន្ធមហាឧបាសក **គង់ ខាត់** បិតាក្មេករបស់សម្តេច និងបុព្វការីជន ញាតិការទាំង៧សណ្តាន នៅវត្តសុវណ្ណគិរី-ដើមធ្នុក ភូមិដើមធ្នុក ឃុំត្រាំង ស្រុកបាធាយ ខេត្តកំពង់ចាម

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយប្រជាពលរដ្ឋ នៅខេត្តកំពត

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៩០ច្បាប់ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៩០ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៨៦ច្បាប់ ទទួលសំណើពីរដ្ឋសភាចំនួន៣ច្បាប់ និងទទួលសំណើពីប្រធានស្តីទីព្រឹទ្ធសភាចំនួន១ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៨ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២០ច្បាប់ ។

**១.២.ឯកឧត្តម ស៊ុម កា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-បំពេញភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងដឹកនាំកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញថ្វាយកម្រងផ្កា គោរពវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ** (ព្រះបរមរតនកោដ្ឋ) នៅព្រះមណ្ឌលតម្កល់ព្រះបរមរូបជិតវិមានឯករាជ្យ រាជធានីភ្នំពេញ

-អញ្ជើញជូនដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៦ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន** :

-បំពេញភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០១លើក និងប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញជូន និងទទួលដំណើរ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទៅចូលរួមកិច្ចប្រជុំប្រធានសភា

ប្រជាជនអាស៊ី-អឺរ៉ុបលើកទី៣ស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បរិស្ថាននិងការអភិវឌ្ឍ ប្រកបដោយចីរភាពនៅតំបន់អាស៊ី និងអឺរ៉ុប

-អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត មកពីប្រទេសបារាំងទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃនៅភូមិចុងកាង ឃុំសណ្តារ ស្រុកលើកដែក ខេត្តកណ្តាល

-បានផ្តល់អាហារូបករណ៍១០០% ដល់សិស្សក្រីក្រចំនួន៨រូប ចូលរៀននៅតាមបណ្តាសាកលវិទ្យាល័យនានា

-អញ្ជើញនាំយកទេយ្យទាន និងទេយ្យវត្ថុទៅប្រគេនព្រះសង្ឃក្នុងឱកាសបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌ

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៤ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក:**

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានប្រជុំចំនួន០២លើក ដើម្បីរៀបចំរបៀបវារៈ និងកំណត់កាលបរិច្ឆេទប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ និងបើកសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ ដែលមានរបៀបវារៈដូចតទៅ:

១.ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ:០៤៨/១៨ និង លេខ:០៤៩/១៨ លគ.គក ចុះថ្ងៃទី០៣ និង០៤ ខែតុលា ឆ្នាំ២០១៨

២.ពិនិត្យសំណើសមាជិកព្រឹទ្ធសភា ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៨ ស្នើសុំព្រឹទ្ធសភាកោះប្រជុំជាវិសាមញ្ញ

៣.ពិនិត្យ និងសម្រេចលើរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៤

៤.កំណត់របៀបវារៈ កាលបរិច្ឆេទ និងសមាសភាពលេខាធិការសម័យប្រជុំលើកទី២ ព្រឹទ្ធសភា នីតិកាលទី៤ ។

**៣. សម័យប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០១លើក** :

ព្រឹទ្ធសភាប្រជុំពេញអង្គចំនួន០១លើក ដែលមានរបៀបវារៈ៖ ស្តាប់របាយការណ៍គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៤ ។

**៤.កិច្ចប្រជុំព្រឹទ្ធសភាវិសាមញ្ញចំនួន០១លើក**

ព្រឹទ្ធសភាប្រជុំជាវិសាមញ្ញចំនួន០១លើក ដែលមានរបៀបវារៈដូចខាងក្រោម:

១.ប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

២.បោះឆ្នោតជ្រើសរើសអនុប្រធានទី១ ព្រឹទ្ធសភា នីតិកាលទី៤ ។

**៥.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែតុលានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម តាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**៥.១.មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពី ការអនុវត្តថវិកា ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ នៅខេត្តប៉ៃលិន

-អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ (HIV/AIDS) នៅខេត្តព្រះសីហនុ

-អញ្ជើញចុះបំពេញបេសកកម្មដើម្បីសិក្សាឈ្វេងយល់អំពី ការអនុវត្តច្បាប់អន្តោប្រវេសន៍ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តព្រះវិហារ។

**៥.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន៣ករណី ផ្ញើពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៩ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងចំនួន១ករណី ផ្ញើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៥ករណី ទទួលឯកសារពាក្យបណ្តឹងពីក្រសួងដែលចម្លងជូនមកព្រឹទ្ធសភាជ្រាបចំនួន៨ករណី និងកំពុងពិនិត្យសិក្សាចំនួន២ករណី

-អញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការទូតសភា

-អញ្ជើញចូលរួមក្នុងកិច្ចពិគ្រោះយោបល់ស្តីពី ការពង្រឹងភាពជាតំណាងរបស់ក្រុមសមាជិកាព្រឹទ្ធសភា និងសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់

-អញ្ជើញចូលរួមក្នុងជំនួបពិភាក្សាដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពសំខាន់ៗ បញ្ហាប្រឈមនានា និងទិសដៅបន្តរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ អញ្ជើញបើកកិច្ចប្រជុំដើម្បីពិនិត្យ និងអនុម័តលើសេចក្តីព្រាងរបាយការណ៍ស្តីពី លទ្ធផលនៃការស្រាវជ្រាវប្រមូលព័ត៌មាននៅខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញបើកកិច្ចប្រជុំដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចចាត់តាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧

-អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំលើកទី២៧ របស់វេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិច (APPF-27)

-អញ្ជើញធ្វើបទបង្ហាញស្តីពី តួនាទី ភារកិច្ច មុខងារ រចនាសម្ព័ន្ធរបស់ព្រឹទ្ធសភា និងតួនាទី ភារកិច្ច សមត្ថកិច្ចរបស់ក្រុមសមាជិកាព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានី-ភ្នំពេញចំនួន៩៥លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យនិងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន១១៥លើក ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមកិច្ចប្រជុំស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាពនៅអាស៊ី-អឺរ៉ុប នៅទីក្រុង Antalya សាធារណ-រដ្ឋតួកគី និងចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៣៩ និងកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាពិភពលោក(ASGP) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) លើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ទទួលបន្ទុកការងារសង្គម និងវប្បធម៌ និងកិច្ចប្រជុំក្រុមប្រឹក្សាប្រតិបត្តិលើកទី១ នៃសភាតំបន់អាស៊ី(APA) នៅទីក្រុងអ៊ីសម៉ៀ នៃសាធារណរដ្ឋតួកគី

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** និងលោកជំទាវ **មាន សំអាន** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋប្រជាមានិតចិន

-លោកជំទាវ **ស៊ីង ស៊ីយុត** អញ្ជើញទទួលបដិសណ្ឋារកិច្ចលោកជំទាវ **ត្រឿង ធិ ម៉ាយ** (Truong Thi Mai) សមាជិកការិយាល័យនយោបាយលេខាធិការមជ្ឈិមបក្ស ប្រធានគណៈចលនាមហាជនមជ្ឈិមវៀតណាម ដឹកនាំគណៈប្រតិភូមកទស្សនកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃអង្គារ ១៣រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**តេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសា